ឆ្នាំទី១៦ លេខ ២៨ សប្តាហ៍ទី ២ ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០១៦ រាជកិច្ច ទំព័រ ៣២៨១

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
ក្រសួងមហាផ្ទៃ
លេខ: ២០៧៤ ប្រក

# ប្រកាស
## ស្តីពី
## ការចុះឈ្មោះក្នុងបញ្ជីសមាគម

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងពាក្យសុំលេខ ០០១ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់លោក **ធុល ទិសាល** ប្រធានសមាគមសហគ្រាសកម្ពុជា ចិន

## សម្រេច

**ប្រការ ១** ..

ត្រូវបានចុះឈ្មោះ **សមាគមសហគ្រាសកម្ពុជា ចិន** ក្នុងបញ្ជីសមាគមនៅក្រសួងមហាផ្ទៃ ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលតាំងនៅផ្ទះលេខ០៣ ភូមិតាងៅក្រោម សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

**ប្រការ ២** ..

**សមាគមសហគ្រាសកម្ពុជា ចិន** ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយមិនមានការរើសអើងការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ។

**ប្រការ ៣** ..

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ និងសាមីសមាគមដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ.ថ្ងៃទី.....ខែ.....ឆ្នាំ២០១៦
ឧ. រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ប៉ុល_លឹម

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ធនាគារជាតិ នៃកម្ពុជា
  (ដើម្បីជូនជ្រាប)
- ដូចប្រការ ៣ (ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ